**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**

គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

លេខ ១៣៧ គល

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

## ការងារជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់ ១៥ស.ម ផ្លូវលំភូមិបឹង(ផ្លូវដំរីជ័យ) ផ្ទៃក្រឡា ៧,៧៧០ម៉ែត្រការ៉េ និង ដាក់លូមូលទំហំ ១.៥ម៉ែត្រ កាត់ទទឹងផ្លូវ០២កន្លែង ក្នុងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ និង ជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់ ២០ស.ម ផ្លូវចូលទីបញ្ចុះសពវៀតណាម ផ្ទៃក្រឡា១០,៤៧៦ម៉ែត្រការ៉េ និងដាក់លូមូលទំហំ ១.៥ម៉ែត្រ ក្នុងសាច់ផ្លូវ ប្រវែង ៦៧០ម៉ែត្រ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧

រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក( គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញ នឹង ដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់១៥ស.ម ផ្លូវលំភូមិបឹង (ផ្លូវដំរីជ័យ) បណ្តោយ១,១១០ម៉ែត្រ ទទឹង៧ម៉ែត្រ ផ្ទៃក្រឡា៧,៧៧០ម៉ែត្រការ៉េ និងដាក់លូមូលទំហំ១.៥ម៉ែត្រ កាត់ទទឹងផ្លូវ០២កន្លែង ចាប់ពីផ្លូវលេខ ១៥១ដល់ផ្លូវកែងភូមិបួនមុខ ក្នុងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ និង ជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់២០ស.ម ផ្លូវចូលទីបញ្ចុះសពវៀតណាម បណ្តោយ ៨៧៣ម៉ែត្រ ទទឹង១២ម៉ែត្រ ផ្ទៃក្រឡា ១០,៤៧៦ម៉ែត្រការ៉េ ចាប់ពីផ្លូវសហ័ន្ធរុស្សី ដល់ ផ្លូវបេតុងចាស់កែងទី២ និងដាក់លូមូលទំហំ ១.៥ម៉ែត្រ ក្នុងសាច់ផ្លូវ ប្រវែង ៦៧០ម៉ែត្រ ចាប់ពីផ្លូវសហ័ន្ធរុស្សី ដល់ ប្រឡាយឆ្ពោះទៅចំការឪឡឹក ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧ ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានលេខ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ ០១៦ ៧៥៥០០៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ០៩:៣០ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៧ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:៣០ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៧

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជា**

**ប្រធានគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ**

**ឃួង ស្រេង**

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ